# ការិយាល័យអ្នកទទួលខុសត្រូវលើការបង្ហាត់សាធារណ: (OSPI)
## ការស្ទាបស្ទង់ភាសាប្រើនៅគេហដ្ឋាន

| | | |
|---|---|---|
| **ឈ្មោះសិស្ស៖** | | **កាលបរិច្ឆេទ៖** |
| **កាលបរិច្ឆេទកើត៖** | **ភេទ៖** | **ថ្នាក់ទី៖** |

**ពាក្យបំពេញដោយ៖**
ឈ្មោះឪពុក/ម្តាយ/អាណាព្យាបាល ________________________ ទំនាក់ទំនងជាមួយសិស្ស ____________
ហត្ថលេខាឪពុក/ម្តាយ/អាណាព្យាបាល ________________________________________

តើលោកអ្នកចង់ឱ្យសាលាទាក់ទងទៅលោកអ្នកជាភាសាអ្វី បើមាន?
________________________________________________________________

**តើកូនរបស់លោកអ្នកបានទទួលការគាំទ្រខាងការអភិវឌ្ឍភាសាអង់គ្លេសតាមរយ:កម្មវិធីបង្ហាត់ប្រើពីរភាសាក្នុងគ្រាអន្តរកាលនៅសាលាដែលកូនលោកអ្នកបានចូលរៀនចុងក្រោយគេដែរឬទេ?** បាន_ ទេ_ មិនដឹង_

| | |
|---|---|
| 1. តើកូនរបស់លោកអ្នកកើតនៅប្រទេសណាដែរ? | ________________ |
| 2. **តើកូនលោកអ្នករៀននិយាយភាសាអ្វីដំបូងគេ?*** | ________________ |
| 3. **តើកូនលោកអ្នកប្រើប្រាស់ភាសាអ្វីច្រើនជាងគេនៅឯគេហដ្ឋាន?*** | ________________ |
| 4. តើក្នុងនាមជាឪពុក/ម្តាយ/អាណាព្យាបាល លោកអ្នកប្រើប្រាស់ភាសាអ្វី (ខ្លះ) ច្រើនជាងគេ នៅពេលនិយាយទៅកាន់កូនលោកអ្នក? | ________________<br>________________ |
| 5. តើកូនលោកអ្នកធ្លាប់បានទទួលការសិក្សាជាផ្លូវការ * នៅក្រៅសហរដ្ឋអាមេរិកឬទេ?<br>(ពីមត្តេយ្យ – ថ្នាក់ទី 12)<br><br>____បាទ ____ទេ<br><br>"ការអប់រំផ្លូវការ" មិនរាប់បញ្ចូលជំរុំជនភាសខ្លួន ឬកម្មវិធីដែលមិនទទួលស្គាល់ ជាផ្លូវការសម្រាប់កុមារៗ។ | ប្រសិនបើធ្លាប់ តើគេបង្ហាត់ជាភាសាអ្វី (ខ្លះ) ដែរ?<br>________________ រយៈពេលប៉ុន្មានខែ? ___ |
| 6. តើកូនរបស់អ្នកចូលរៀននៅសហរដ្ឋអាមេរិកដំបូងគេនៅពេលណា?<br>(ពីមត្តេយ្យ–ថ្នាក់ទី 12) | ________________________<br>ខែ ថ្ងៃ ឆ្នាំ |

**WAC 392-160-005៖ «ភាសាបង្កោល» សំដៅលើភាសាដែលប្រើញឹកញាប់បំផុតដោយសិស្ស (មិនចាំបាច់តែឪពុកម្តាយ អាណាព្យាបាល ឬអ្នកផ្សេងទេ) សម្រាប់ការប្រាស្រ័យទាក់ទងក្នុងលំនៅដ្ឋានរស់នៅរបស់សិស្ស។*

*Note to district: A response of a language other than English to question #2 OR question #3 triggers ELL placement testing.*

# គោលបំណងការសិក្សាអង្កេតភាសាប្រើនៅផ្ទះ

ការសិក្សាអង្កេតភាសាប្រើនៅផ្ទះ (Home Language Survey) ត្រូវបានផ្តល់ជូនចំពោះសិស្សទាំងអស់ដែលចុះឈ្មោះនៅសាលារដ្ឋវ៉ាស៊ីនតោន Washington។ ព័ត៍មានខាងក្រោមនេះ ជួយឆ្លើយសំណួរមួយចំនួន ដែលលោកអ្នកអាចមានអំពីសំណុំបែបបទនេះ។

**តើអ្វីទៅជាគោលបំណងការសិក្សាអង្កេតភាសាប្រើនៅផ្ទះ (Home Language Survey)?**
គោលបំណងចំបងនៃការសិក្សាអង្កេតភាសាប្រើនៅផ្ទះ (Home Language Survey) គឺដើម្បីជួយកំណត់អត្តសញ្ញាណសិស្សនានាដែលអាចមានគុណសម្បត្តិគ្រប់គ្រាន់សម្រាប់ការឧបត្ថម្ភគាំទ្រដើម្បីជួយពួកគេអភិវឌ្ឍន៍ជំនាញភាសាអង់គ្លេសដែលចាំបាច់សម្រាប់ជោគជ័យនៅក្នុងថ្នាក់រៀន ហើយដែលអាចមានគុណសម្បត្តិគ្រប់គ្រាន់សម្រាប់សេវាកម្មផ្សេងៗទៀត។ វាមានសារៈសំខាន់ណាស់ដែលថាព័ត៍មាននេះត្រូវបានគេធ្វើកំណត់ត្រាយ៉ាងត្រឹមត្រូវ ដោយសារវាអាចប៉ះពាល់ចំពោះភាពមានសិទ្ធិស្របច្បាប់របស់សិស្សនានាសម្រាប់សេវាកម្មនានាដែលពួកគេត្រូវការឱ្យមានជោគជ័យនៅសាលារៀន។ ការធ្វើតេស្តអាចជាការចាំបាច់ដើម្បីកំណត់ថាតើ ភាសាអង់គ្លេស និងការឧបត្ថម្ភគាំទ្រអប់រំបន្ថែម ដែលត្រូវការឬអត់។ ពុំមានសិស្សនឹងត្រូវបានដាក់នៅកម្មវិធីអភិវឌ្ឍន៍ភាសាអង់គ្លេស ដោយផ្អែកលើការឆ្លើយតបចំពោះសំណុំបែបបទនេះតែមួយគត់ឡើយ។

**ហេតុអ្វីលោកអ្នកសាកសួរអំពីភាសាដើម និងភាសានានាទៀតរបស់សិស្សដែលប្រើប្រាស់នៅផ្ទះ?**
សំណួរទាំងពីរអំពីភាសារបស់សិស្ស ជួយយើខ្ញុំកំណត់៖

- ប្រសិនបើសិស្សអាចមានសិទ្ធិស្របច្បាប់សម្រាប់ការជួយជាមួយការសិក្សាសាភាអង់គ្លេស និង
- ថាតើបុគ្គលិកនៅសាលា គួរតែយល់ដឹងអំពីភាសាផ្សេងៗទៀតដែលត្រូវប្រើប្រាស់ដោយសិស្សនៅផ្ទះឬអត់។

ភាសាដែលកូនលលោកអ្នកបានរៀនលើកដំបូង អាចមានខុសៗគ្នាពីភាសាដែលកូនលោកអ្នកប្រើប្រាស់សម្រាប់ការប្រាស្រ័យទាក់ទងនៅផ្ទះនាពេលបច្ចុប្បន្ននេះ។ ចម្លើយតបនានាចំពោះសំណួរទាំងពីរនេះ នឹងជួយសាលាក្នុងការផ្តល់ជូនការណែនាំសមរម្យចំពោះតម្រូវការនានារបស់សិស្សជាលក្ខណៈបុគ្គល ក៍ដូចជាការជួយជាមួយនឹងតម្រូវការប្រាស្រ័យទាក់ទងដែលអាចកើតមានឡើង។ សិស្សនានាដែលបានសិក្សាភាសាមួយលើកដំបូង ក្រៅពីភាសាអង់គ្លេស អាចមានគុណសម្បត្តិគ្រប់គ្រាន់សម្រាប់ឧបត្ថម្ភគាំទ្របន្ថែម។ ទោះជាសិស្សនានាដែលនិយាយភាសាអង់គ្លេសល្អក៏ដោយ ក៏អាចនៅតែត្រូវការការឧបត្ថម្ភគាំទ្រក្នុងការអភិវឌ្ឍន៍ជំនាញភាសាដែលត្រូវការដើម្បីជោគជ័យនៅសាលាផងដែរ។

**ហេតុអ្វីលោកអ្នកសាកសួរអំពីទីកន្លែងសិស្សបានកើត?**
ព័ត៍នេះ ជួយសាលាថ្នាក់ស្រុក និងរដ្ឋ កំណត់ថាតើ សិស្សបំពេញតាមការកំណត់អត្ថន័យអំពីអន្តោប្រវេសន៍សម្រាប់គោលបំណងនានានៃការផ្តល់ថវិកាសហព័ន្ធឬទេ។ ហើយនេះត្រូវអនុវត្ត បើទោះជានៅពេលណាមាតាបិតាសិស្សជាពលរដ្ឋអាមេរិកទាំងពីរនាក់ក៏ដោយ, ប៉ុន្តែសិស្សកើតនៅក្រៅសហរដ្ឋអាមេរិក the United States។ សំណុំបែបបទនេះមិនត្រូវបានគេប្រើប្រាស់ដើម្បីកំណត់អត្តសញ្ញាណសិស្សនានាដែលអាចគ្មានឯកសារ។

**ហេតុអ្វីលោកអ្នកសាកសួរអំពីការសិក្សាពីមុនៗរបស់សិស្សខ្ញុំ?**
ព័ត៍អំពីការសិក្សារបស់សិស្ស នឹងជួយធានាថា ការសិក្សារបស់សិស្សទាំងនៅខាងក្នុង និងនៅខាងក្រៅសហរដ្ឋអាមេរិក the United States ត្រូវបានគេចាត់ទុកនៅក្នុងការផ្តល់ជូនអនុសាសន៍ផ្សេងៗដែលបានរៀបចំឡើងសម្រាប់ការចូលរួមក្នុងកម្មវិធី និងសេវាកម្មនានានៅថ្នាក់ស្រុក។ ប្រវត្តិការសិក្សារបស់សិស្ស ក៏ជាព័ត៍មានសំខាន់ផងដែរ ដើម្បីជួយកំណត់ថាតើ សិស្សកំពុងតែមានដំណើរការជឿនលឿនគ្រប់គ្រាន់តាមស្តង់ដាររដ្ឋ ដោយផ្អែកលើប្រវត្តិការសិក្សារបស់សិស្សពីមុនរបស់ពួកគេឬទេ។

សូមអរគុណលោកអ្នកចំពោះការផ្តល់ជូនព័ត៏ដែលត្រូវការសម្រាប់ការសិក្សាអង្កេតភាសាប្រើនៅផ្ទះ (Home Language Survey)។ សូមទាក់ទងមកសាលាថ្នាក់ស្រុកលោកអ្នក បើលោកអ្នកមានសំណួរនានាបន្ថែមទៀតអំពីសំណុំបែបបទនេះ ឬអំពីសេវាកម្មនានាដែលអាចប្រព្រឹត្តទៅបានៅសាលាកូនលោកអ្នក។